**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខៈ ០៥៧/២១ អអរ**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តព្រៃវែង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម សៀង សារ៉ាត ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង**
- **លោក ស៊ី តុង មេឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្តីផ្តើម

ខេត្តមានស្រុកចំនួន១២ ក្រុង០១ ឃុំ១១២ សង្កាត់ចំនួន០៤ និងមានភូមិ១.១៤៩ មានប្រជាពលរដ្ឋសរុប១.២៤៩.៨១៣នាក់ ស្រីចំនួន៦៤៥.២៧០នាក់ ស្មើនឹង២៩០.១០៥គ្រួសារ និងជាខេត្តមានសក្តានុពលផ្នែកកសិកម្មដែលមានចំនួន ៦៣,៩% សិប្បកម្មមានចំនួន០,២% សេវាកម្មមាន៣៥,៩%។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្តបានខិតខំបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រុមប្រឹក្សាខេត្ត បានបើកកិច្ចប្រជុំជាទៀងទាត់ស្របតាមប្រតិទិននៃកិច្ចប្រជុំសាមញ្ញ និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា
- បានប្រជុំសាមញ្ញរបស់ខ្លួនបានចំនួន ២០លើក និងប្រជុំវិសាមញ្ញចំនួន ០៤លើក
- បានរៀបចំបែងចែកការទទួលខុសត្រូវលើកិច្ចប្រតិបត្តិការ ដែលជួយសម្រួលដល់ការបំពេញតួនាទី ភារកិច្ច របស់ខ្លួនសម្រាប់ការចុះទៅមូលដ្ឋាន
- ក្រុមប្រឹក្សាបានទំនាក់ទំនង ជាមួយគណៈអភិបាល មន្ទីរ អង្គភាពជំនាញ មានភាពរលូន និងល្អប្រសើរ ដោយបានអញ្ជើញ ឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត យ៉ាងទៀងទាត់
- អនុម័តផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ ដែលជាចក្ខុវិស័យអភិវឌ្ឍខេត្ត ក្នុងអាណត្តិក្រុមប្រឹក្សា និងពិនិត្យ ផ្តល់យោបល់ អនុម័តកម្មវិធីវិនិយោគ៣ឆ្នាំរំកិលខេត្តរបស់រដ្ឋបាលខេត្ត
- គាំទ្រការរៀបចំ និងអនុវត្តគម្រោងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ឆ្នាំ២០២០មាន៖ រដ្ឋបាលខេត្តមានចំនួន២១គម្រោង រដ្ឋបាលក្រុង ស្រុក មានចំនួន៣៦គម្រោង រដ្ឋបាលឃុំ សង្កាត់មានចំនួន១៤៧គម្រោង និងមានគម្រោងដៃគូអភិវឌ្ឍ(ADB)មានចំនួន០៦គម្រោង
- បានចូលរួមក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 តាមរយៈការចុះផ្សព្វផ្សាយអំពីយន្តការទប់ស្កាត់ជំងឺ ចុះសួរសុខទុក្ខប្រជាពលរដ្ឋ បានចូលរួមបរិច្ចាគជាថវិកាចំនួន ៥.១០០.០០០រៀល ជូនដល់គណៈកម្មការCOVID-19ខេត្ត និងបានឧបត្ថម្ភជាសាច់ប្រាក់ជូនដល់គ្រួសារក្រីក្រចំនួន៦០.៣៥៨គ្រួសារ ព្រមទាំងបានឧបត្ថម្ភជាសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះចំនួន៣.២៨២នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន១.៤៣៦នាក់។

❖ **ឃុំក្របៅ ស្រុកកំចាយមារ**

- ការងារកសិកម្ម៖ មានផ្ទៃដីបង្កបង្កើនផលចំនួន ១.៣៨៤ហិកតា ស្រូវស្រាល ៥៦៣ហិកតា ស្រូវកណ្តាល ៣៦០ហិកតា ស្រូវធ្ងន់ ៤៦១ហិកតា មានចិញ្ចឹមគោ ចំនួន១.២០១ក្បាល ក្របី ៩៥០ក្បាល ជ្រូក ៨៤៥ក្បាល មាន់ចំនួន ១២.១៩៨ក្បាល ទា ចំនួន១.៨៤៦ក្បាល និងមាន

ដំណាំរួមផ្សំផ្ទុំចជា ដំឡូងមី ១.០៣២ហិកតា ដំណាំកៅស៊ូ ៣៥៦.១៦ហិកតា ដំណាំអំពៅ ២១០ហិកតា

- ការងារអប់រំ៖ សាលាមត្តេយ្យរដ្ឋចំនួន ០៤កន្លែង សាលាបឋមសិក្សា ០៦កន្លែង អនុវិទ្យាល័យ ០១កន្លែង
- ការងារសេវាសាធារណៈ៖ បានចិត្តទុកដាក់អនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា និងដោះស្រាយរាល់តម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ នៅមូលដ្ឋានប្រកបដោយគុណធម៌ តម្លាភាព និងមានប្រសិទ្ធភាពខ្ពស់
- ការងារសណ្តាប់ធ្នាប់សាធារណៈ៖ ដោយអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ការងារការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈក្នុងឃុំទាំងមូលជារួម គឺរក្សានូវសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់ សាធារណៈជូនប្រជាពលរដ្ឋ
- ការងារសង្គមកិច្ច៖ បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ ស្ត្រីងាយរងគ្រោះ និងកុមារ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩៖ ដោយបានអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងវិធានការរបស់ក្រសួងសុខាភិបាល យន្តការទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ-១៩ ឃុំបានរៀបចំកន្លែងដាក់ចត្តាឡីស័កឃុំ ដើម្បីគ្រប់គ្រងលើផ្នែកសុខភាព និងការដាក់ឱ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ ចំពោះប្រជាពលរដ្ឋមកពីក្រៅប្រទេស។

## III. ទិសដៅការងារបន្ត

- ❖ **ក្រុមប្រឹក្សាខេត្ត**

- បន្តរៀបចំកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ វេទិកាផ្សព្វផ្សាយ ផែនការចុះគាំទ្រនៅមូលដ្ឋាន ដើម្បីប្រមូលយកតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ
- បន្តការគាំទ្រអនុវត្តមុខងារ ដែលបានប្រគល់ដោយក្រសួងស្ថាប័នថ្នាក់ជាតិ ដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
- ជំរុញ និងគាំទ្រ ការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ ដើម្បីបង្កិតសេវាសាធារណៈឱ្យកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងកសាងកម្មវិធីវិនិយោគ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ឱ្យស្របតាមតម្រូវការក្នុងការអភិវឌ្ឍខេត្ត

- បន្តពិនិត្យ ផ្តល់យោបល់ និងអនុម័ត កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត និងការរៀបចំយុទ្ធសាស្ត្រថវិកាឱ្យបានល្អប្រសើរ និងជោគជ័យ ដើម្បីឆ្លើយតបតាមតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន
- ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា ឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តិនានា និងបែងចែកភារកិច្ចចូលរួមគាំទ្រការងារ រាល់ការចេញសេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សា
- បន្តការខិតខំ និងគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទផ្សេងៗ ក្រៅប្រព័ន្ធតុលាការ និងតាមរយៈការិយាល័យប្រជាពលរដ្ឋ
- ពង្រឹងទំនាក់ទំនង សាមគ្គីភាពឯកភាពផ្ទៃក្នុង សហការរួមគ្នាអនុវត្តការងារ តាមប្រព័ន្ធរដ្ឋបាលឯកភាព រវាងក្រុមប្រឹក្សា និងគណៈអភិបាល ធ្វើយ៉ាងណាឱ្យរដ្ឋបាលខេត្តមានការអភិវឌ្ឍជឿនលឿន តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ជំរុញ រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បន្តយកចិត្តទុកដាក់អនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
- បន្តគាំទ្រ និងជំរុញ ការទប់ស្កាត់ការរីករាលដាលជំងឺCOVID-19 និងបន្តចូលរួមក្នុងការផ្សព្វផ្សាយនូវវិធានការ របស់រាជរដ្ឋាភិបាល និងរបស់ក្រសួងសុខាភិបាល។

❖ **ឃុំក្របៅ ស្រុកកំចាយមារ**

- បន្តយកចិត្តទុកដាក់បម្រើសេវារដ្ឋបាល និងដោះស្រាយទំនាស់ផ្សេងៗជូនប្រជាពលរដ្ឋឱ្យលឿន រហ័ស និងមិនរើសអើង។
- បន្តការខិតខំពង្រឹងការអនុវត្តន៍គោលនយោបាយភូមិឃុំ សង្កាត់ មានសុវត្ថិភាពប្រកបដោយប្រសិទ្ធភាព
- បន្តការចុះពង្រឹងការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយក្នុងមូលដ្ឋានឱ្យបានល្អ
- បន្តការផ្សព្វផ្សាយពីវិធានការការពារ និងទប់ស្កាត់ ជំងឺកូវីដ-១៩
- បន្តការអនុវត្តផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យសមស្របទៅតាមផែនការដែលបានគ្រោងទុក៕

ថ្ងៃអង្គារ ១២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១